**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Feb-2013, 11:38
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់អង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងការជំទាស់របស់ អៀង សារី ទាក់ទងទៅនឹងសក្ខីកម្មរបស់សាក្សី TCW-624 តាមប្រព័ន្ធសោតទស្សន៍**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ

នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម

លោក Michael G.KARNAVAS
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

## ចម្លើយតប

១. នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ដោយចាត់ការទៅលើសំណើមួយមកពីមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា[1] អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានជូនដំណឹងដល់ភាគីនានាថា ខ្លួនបានពិចារណាចំពោះសាក្សី TCW-624 នៅក្នុងចំណោមបុគ្គលទាំងឡាយដែល “មានភាពពាក់ព័ន្ធបំផុត” ទៅនឹងផ្នែកនៃសវនាការដែលទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដូច្នេះគឺជាអ្នកដែល “ទំនងបំផុតដែលត្រូវផ្តល់សក្ខីកម្មនៅសវនាការ”[2]។ ក្រោយមក អង្គជំនុំជម្រះបានដាក់សៀវភៅមួយក្បាលដែលនិពន្ធដោយសាក្សី TCW-624 ចូលទៅក្នុងសំណុំរឿង ដែលអង្គជំនុំជម្រះយល់ឃើញថា “មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត” និងដើម្បីឲ្យត្រូវតាមលក្ខណៈវិនិច្ឆ័យសម្រាប់ភាពអាចទទួលយកបាន នៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[3]។

២. តាមអនុស្សរណៈ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (“WESU”) បានរាយការណ៍ពីការប្រាស្រ័យទាក់ទងរបស់ខ្លួនជាមួយនឹងសាក្សី TCW-624 ហើយបានផ្តល់ប្រឹក្សាដល់អង្គជំនុំជម្រះ អំពីសំណើរបស់គាត់ដើម្បីឲ្យបានផ្តល់សក្ខីកម្មដោយ “សវនាការតាមប្រព័ន្ធសោតទស្សន៍” (“សំណើអំពីប្រព័ន្ធសោតទស្សន៍”)[4]។

៣. នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ ដូចដែលបានបង្គាប់ដោយអង្គជំនុំជម្រះ[5] សហព្រះរាជអាជ្ញាបានផ្តល់ប្រឹក្សា ដល់ភាគីនានា អំពីទំព័រជាក់លាក់នៃសៀវភៅមួយក្បាល ដែលនិពន្ធដោយសាក្សី TCW-624 ដែលសហព្រះរាជអាជ្ញា យល់ឃើញថាមានការពាក់ព័ន្ធ ទៅនឹងសក្ខីកម្មរបស់គាត់ ហើយបានស្នើថា គេគួរផ្តល់សំណៅឯកសារជាអេឡិចត្រូនិចនៃសៀវភៅនេះ ឲ្យទៅសាក្សីរូបនេះ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន[6]។

---

[1] **E9/10.1** ឧបសម្ព័ន្ធ ឃៈ សេចក្តីសង្ខេបសាក្សី ជាមួយនឹងចំណុចនៃការចោទប្រកាន់ - សាក្សីដែលស្នើឡើងដោយក្រុមមេធាវីការពារក្តី នួន ជា, ២៣ កុម្ភៈ ២០១១ ត្រង់ទំព័រទី ៤៧។

[2] **E236/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីៈ ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១, ២ តុលា ២០១២ ត្រង់កថាខណ្ឌ ១។

[3] **E260** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីៈ “ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីៗចូលក្នុងសំណុំរឿងពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី [ឈ្មោះត្រូវបានលុបចេញ]”, ១៨ មករា ២០១៣ ត្រង់កថាខណ្ឌ ៦។

[4] **E236/1/4** អនុស្សរណៈរបស់អ្នកសម្របសម្រួល WESU ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងៈ “សម្ងាត់ សំណើសុំផ្តល់សក្ខីកម្មរបស់សាក្សី TCW-624 [ឈ្មោះត្រូវបានលុបចេញ] តាមប្រព័ន្ធសោតទស្សន៍”, ៨ កុម្ភៈ ២០១៣ ត្រង់កថាខណ្ឌ ២។

[5] **E260** កំណត់សម្គាល់*ខាងលើ* លេខ៣ ត្រង់កថាខណ្ឌ ៦។

[6] អ៊ីមែលរបស់ព្រះរាជអាជ្ញារង ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់ៈ “ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង ឯកសារលេខ E260 ទាក់ទងនឹងទំព័រនៃសៀវភៅរបស់សាក្សី [ឈ្មោះត្រូវបានលុបចេញ] ដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលសវនាការ”, ១៥ កុម្ភៈ ២០១៣។

៤. នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ មេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី ("មេធាវីការពារក្តី") បានដាក់ការជំទាស់របស់ខ្លួនទៅនឹងសំណើអំពីប្រព័ន្ធសោតទស្សន៍ ដោយសុំឲ្យអង្គជំនុំជម្រះបដិសេធកុំឲ្យធ្វើការកោះហៅសាក្សី TCW-624 អ្វីឡើយ។ ឬម្យ៉ាងវិញទៀត សុំឲ្យស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះដោយបុគ្គលផ្ទាល់ ("សំណើ")[7]។ បន្ថែមលើនេះ មេធាវីការពារក្តីស្នើថា បើសាក្សី TCW-624 ត្រូវផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ នោះគេត្រូវផ្តល់ "ទម្ងន់តិចតួចជាង"[8] ឲ្យដល់សក្ខីកម្មរបស់គាត់។

៥. ទាក់ទងទៅនឹងភាពមិនត្រឹមត្រូវដ៏សំខាន់តាមអង្គច្បាប់ និងអង្គហេតុនៅក្នុងសំណើនេះ ហើយនិងការមិនយកចិត្តទុកដាក់ទៅលើសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះនេះ សហព្រះរាជអាជ្ញាសូមដាក់ជូននូវចម្លើយតបនេះ។ សហព្រះរាជអាជ្ញា សូមស្នើបន្ថែមទៀតថា ការដាក់ជូននេះគួរត្រូវបានចាត់ថ្នាក់ជា *សាធារណៈ* ពីព្រោះវាត្រូវ បានលុបចេញខ្លះដើម្បីដកយកព័ត៌មានសម្ងាត់ទាំងឡាយណាដែលពាក់ព័ន្ធនឹងសាក្សីរូបនេះចេញ។

៦. សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា សំណើនេះគួរត្រូវបានបដិសេធចោលទាំងស្រុង ហើយគួរបន្តធ្វើសក្ខីកម្មសាក្សី TCW-624 តាមប្រព័ន្ធសោតទស្សន៍។

៧. ទីមួយ សហព្រះរាជអាជ្ញា សូមដាក់បញ្ចូលដោយមានការយោង និងសូមស្នើដោយគោរព សូមឲ្យអង្គជំនុំជម្រះ ធ្វើការយោងទៅដល់ការដាក់ជូននូវសេចក្តីសន្និដ្ឋានពិស្តារពីមុនៗរបស់សហព្រះរាជអាជ្ញា ស្តីពីច្បាប់ជាធរមាន នៅក្នុងចម្លើយតបទៅនឹងការជំទាស់ដែលមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំង របស់ជនជាប់ចោទ អៀង សារី ស្តីពីសក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1[9] និងសាក្សីអ្នកជំនាញ TCE-38[10]។

៨. ទីពីរ សហព្រះរាជអាជ្ញា សូមបញ្ជាក់អះអាងឡើងវិញជាថ្មីអំពីគោលជំហររបស់ខ្លួនកាលពីមុនថា ការពោលអះអាង របស់ក្រុមមេធាវីការពារក្តី ស្តីពីផលប៉ះពាល់នៃការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ស្តីពីសិទ្ធិក្នុងការតទល់ជាមួយសាក្សី[11] ឬ ថាការផ្តល់សក្ខីកម្មនេះគួរតែត្រូវបានយល់

---

[7] **E236/1/4/2** សេចក្តីជូនដំណឹងរបស់ អៀង សារី អំពីការជំទាស់ទៅនឹងសំណើរបស់សាក្សីដែលមានរហស្សនាម TCW-624 ដែលស្នើសុំផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍, ២១ កុម្ភៈ ២០១៣ ត្រង់ទំព័រទី ៥។

[8] **E236/1/4/2** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ១៣។

[9] **E236/1/1/3** ចម្លើយតបជាបន្ទាន់របស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អៀង សារី ពាក់ព័ន្ធនឹងសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1, ដោយមានឧបសម្ព័ន្ធ, ១១ ធ្នូ ២០១២ ត្រង់កថាខណ្ឌ ៤-២១។

[10] **E236/1/4/2** សំណើ, កំណត់សម្គាល់*ខាងលើ* លេខ៧ ត្រង់កថាខណ្ឌ ៥-៩ និង ១២-១៣។

[11] ឯកសារលេខ **E236/1/4/2** *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី៥-៩ និងទី១២-១៣។

ព្រមផ្តល់ឲ្យនូវ "ទម្ងន់ស្រាលជាង"[12] *គឺមិនត្រឹមត្រូវខាងអង្គច្បាប់ទាំងស្រុង*[13]។ តាមច្បាប់ជាធរមាន -និងផ្ទុយពីទម្លាប់អនុវត្តនៅសហរដ្ឋអាមេរិក- ការតទល់របស់សាក្សី តាមរយៈប្រព័ន្ធសោតទស្សន៍ស្របតាមវិធីសាស្ត្រនានា ដែលអង្គជំនុំជម្រះរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា តែងតែចេញដីកាសម្រេច គឺ *ចាត់ទុកដូចជាការតទល់គ្នាដោយផ្ទាល់* និងដែលបំពេញទាំងស្រុងតាមលក្ខខណ្ឌស្តីពីសិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ។ ក្រុមមេធាវីការពារក្តី បានពឹងផ្អែកដោយខុសប្លែកពីគ្នាទៅលើករណីរឿងក្តីរបស់ Tadic (ឆ្នាំ១៩៩៦)[14], ករណីរឿងក្តីរបស់ Bogosora និងគូរកន (ឆ្នាំ២០០៤)[15], ហើយនឹងករណីរឿងក្តីរបស់ Ziyiranyirazo (ឆ្នាំ២០០៦)[16]ក្នុងការគាំទ្រចំពោះសំណូមពរដែលសុំឲ្យអនុញ្ញាតក្នុងការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ដែលបដិសេធចំពោះ អៀង សារី នូវ "សិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយមានវត្តមានរបស់គាត់ ទាំងនៅចំពោះមុខតុលាការ និងទាំងនៅចំពោះមុខរបស់សាក្សីទាំងឡាយដែលផ្តល់សក្ខីកម្មប្រឆាំងនឹងរូបគាត់"[17] និងថា ការផ្តល់សក្ខីកម្មបែបនេះ បើសិនជាត្រូវបានអនុញ្ញាតឲ្យបន្តធ្វើនោះ គួរតែត្រូវបានផ្តល់ឲ្យនូវ "ទម្ងន់ដែលស្រាលជាង"[18]។ សេចក្តីសម្រេចជាពិសេសទាំងនេះទោរទន់ទៅរកការឆ្លុះបញ្ចាំងឲ្យឃើញពីភាពខុសប្លែកគ្នានៅក្នុងយុត្តិសាស្ត្រដែលស្របទៅតាមបច្ចេកវិទ្យាថ្មី និងមិនធ្វើការឆ្លុះបញ្ចាំងដោយត្រឹមត្រូវពីសភាពជារួមនៃច្បាប់ដែលត្រូវបានពិនិត្យមើលឡើងវិញ និងធ្វើសេចក្តីសង្ខេប ឧទាហរណ៍ដូចជា នៅក្នុងករណីរឿងក្តីរបស់ *Milutinivić* ដែលចុះកាលបរិច្ឆេទចាប់ពីឆ្នាំ២០០៦មកដែរ៖

> *យុត្តិសាស្ត្ររបស់តុលាការគាំទ្រដល់អំណះអំណាងដែលថា សក្ខីកម្មរបស់សាក្សីនានាតាមរយៈប្រព័ន្ធសោតទស្សន៍ <u>គួរតែត្រូវបានផ្តល់នូវស្ថានទម្ងន់ជាភរនីយភាពដូចគ្នា នឹងសក្ខីកម្មដែលមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការដែរ</u> និងថា វិធានការណ៍បែបនេះ <u>គឺវាមិនរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោល សាក្សីរបស់ភាគីបដិបនិងតទល់ជាមួយសាក្សីដោយផ្ទាល់នោះឡើយ</u>*[19] ។

---

[12] ឯកសារលេខ **E236/1/4/2** *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១៣ ។

[13] ឯកសារលេខ **E236/1/4/2** *ដូចគ្នានឹងខាងលើកន្លែងដែល* ផ្នែកទីII។

[14] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Duško Tadić*, សំណុំរឿងលេខ IT-94-1-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីដែលស្នើសុំឲ្យកោះហៅនិងការពារសាក្សីរបស់ចុងចោទ និងស្តីពីការផ្តល់ភស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី២៥ មិថុនា ១៩៩៦។

[15] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Théoneste Bagosora និងគូរកន*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចស្តីពីសំណើរបស់រដ្ឋអាជ្ញាសុំឲ្យផ្តល់សក្ខីកម្មរបស់សាក្សីBT ធ្វើឡើងតាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី៨ តុលា ២០០៤។

[16] *ករណីរឿងក្តីរបស់ Zigiranyirazo ទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ ICTR-2001-73-AR73, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីបញ្ហាបន្ទាន់បង្អំ, ចុះថ្ងៃទី៣០ តុលា២០០៦។

[17] ឯកសារលេខ **E236/1/4/2** សំណើ, កំណត់សម្គាល់លេខ៧ *ខាងដើម* ត្រង់កថាខណ្ឌទី១០។

[18] ឯកសារលេខ **E236/1/4/2** *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១៣ ។

[19] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milan Milutinović* និងគូរកន, សំណុំរឿងលេខ IT-05-87-T, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាដែលស្នើសុំវិធានការការពារ និងសុំឲ្យស្តាប់សក្ខីកម្មរបស់សាក្សីតាមរយៈប្រព័ន្ធសោតទស្សន៍ ចុះថ្ងៃទី១៥ សីហា ២០០៦ ត្រង់កថាខណ្ឌទី៣។

៩. ទីបី សហព្រះរាជអាជ្ញាបានទទួលយល់ព្រមជាមួយក្រុមមេធាវីការពារក្តីថាការផ្តល់វិញ្ញាបនប័ត្រពេទ្យមិនអាចលើកលែងឲ្យអង្គជំនុំជម្រះពីការពិនិត្យ លើរាល់កត្តាទាំងអស់ដែលទាក់ទងទៅនឹងការធ្វើតេស្តសាកល្បងស្តីពី "ផលប្រយោជន៍ដល់យុត្តិធម៌" ក្នុងការអនុញ្ញាតឲ្យផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍[20]។ ក៏ប៉ុន្តែ ដូចដែលបានបង្ហាញជូនដោយការធ្វើការស្ទង់មតិនាពេលថ្មីនេះរបស់សហព្រះអាជ្ញាទៅលើសេចក្តីសម្រេចចំនួន៣១របស់តុលាការ ICTY ដែលមានស្រាប់អាចឲ្យរកបាននៅក្នុងសំណុំរឿង[21] *គ្មានសេចក្តីសម្រេចណាមួយទាល់តែសោះ* នៅក្នុងសំណុំរឿងនៅឯតុលាការ ដែលការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ត្រូវបានបដិសេធ ដោយផ្អែកលើវិញ្ញាបនប័ត្រពេទ្យមួយដែលមកទល់នឹងពេលនេះ។ សាក្សីTCW-624 បានផ្តល់ដោយមានការទទួលស្គាល់ របស់ក្រុមមេធាវីការពារក្តីដោយផ្ទាល់ នូវ "លិខិតមួយមកពីវេជ្ជបណ្ឌិតឯកទេសខាងបេះដូងដែលលើកអនុសាសន៍ ថាគាត់នឹងមិនធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីផ្តល់សក្ខីកម្មនោះទេ"[22]។ នេះគឺជាការគូសបញ្ជាក់ពីមតិផ្នែកវេជ្ជសាស្ត្ររបស់អ្នកឯកទេសដែលទទួលបន្ទុកព្យាបាល ដែលបានរកឃើញថា "ការធ្វើដំណើរមកកាន់តំបន់អាស៊ី អាច*នឹងមានគ្រោះថ្នាក់ដល់សុខភាពរបស់គាត់* និងជាការទទួលភារៈដែលមិនមានភាពឈ្លាសវៃ *នាពេលបច្ចុប្បន្ននិងដែលអាចទាយទុកជាមុនបានសម្រាប់ពេលអនាគត*"[23]។ ជាបន្ថែមពីលើនេះ សហព្រះរាជអាជ្ញាបានសង្កេតឃើញថា គ្រូពេទ្យឯកទេសដែលទទួលបន្ទុកព្យាបាលបានផ្តល់នូវ "ការធ្វើរោគវិនិច្ឆ័យ" ដែលជាដើមអាទីដែលរៀបរាប់រឿងរ៉ាវសម្រាប់ជាអនុសាសន៍របស់ពេទ្យដែលប្រឆាំងនឹងការធ្វើដំណើរ[24]។ ព័ត៌មានលម្អិតរបស់ពេទ្យ នៅពេលដែលមានស្រាប់អាចឲ្យអង្គជំនុំជម្រះងាយរកបាននោះ ត្រូវបានកោសលុបចេញខ្លះយ៉ាងត្រឹមត្រូវនៅមុនពេលធ្វើការផ្សព្វផ្សាយដល់ភាគីនានាឲ្យបានជ្រាប។ នៅក្នុង កាលៈទេសៈទាំងនេះ អាចនឹងមិនមានការមន្ទិលសង្ស័យទេថា លក្ខណៈវិនិច្ឆ័យស្តីពីការគ្មានសមត្ថភាពក្នុងការមកផ្តល់សក្ខីកម្មដោយផ្ទាល់ខ្លួន[25] គឺត្រូវបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌ ។

១០. ទីបួន សាក្សី TCW-624 មិនបានស្នើឡើងដោយសហព្រះរាជអាជ្ញាទេ ហើយយើងសូមធ្វើការសន្និដ្ឋានថា អង្គជំនុំជម្រះបានធ្វើការសម្រេចរួចហើយថា សក្ខីកម្មរបស់សាក្សី TCW-624 នឹង

---

[20] ឯកសារលេខ **E236/1/4/2** សំណើ, កំណត់សម្គាល់លេខ៧ *ខាងដើម* ត្រង់កថាខណ្ឌទី១០។ ឯកសារលេខ **E236/1/1/3** TCCP-1 ចម្លើយតប, កំណត់សម្គាល់លេខ៩ ខាងដើម ត្រង់កថាខណ្ឌទី៩។

[21] ឯកសារលេខ **E236/1/13.2.1** ឧបសម្ព័ន្ធទី១: តារាងវិភាគទៅលើសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTY ទាក់ទងនឹងការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ចុះថ្ងៃទ១១ ធ្នូ ២០១២។

[22] ឯកសារលេខ **E236/1/4/2** សំណើ, កំណត់សម្គាល់លេខ៧ *ខាងដើម* ត្រង់កថាខណ្ឌទី១០។

[23] ឯកសារលេខ **E236/1/4/1.1** លិខិតពីលោក Robin S Freedburg MD ផ្ញើជូនអង្គភាព WESU, ចុះថ្ងៃទី១៤ កុម្ភៈ ២០១៣ [ការសង្កត់ធ្ងន់បន្ថែមដោយអក្សរទ្រេត]។

[24] ឯកសារលេខ **E236/1/4/1.1** *ដូចគ្នានឹងខាងលើកន្លែងដែល។*

[25] ឯកសារលេខ **E236/1/4/2** សំណើ, កំណត់សម្គាល់លេខ៧ *ខាងដើម* ត្រង់កថាខណ្ឌទី៩។ ឯកសារលេខ **E236/1/1/3** TCCP-1 ចម្លើយតប, កំណត់សម្គាល់លេខ៩ ខាងដើម ត្រង់កថាខណ្ឌទី៨។

បំពេញបាននូវលក្ខណៈវិនិច្ឆ័យដ៏មានសារសំខាន់យ៉ាងគ្រប់គ្រាន់[26]។ អង្គជំនុំជម្រះបានពិចារណាលើសៀវភៅមួយក្បាលដែលបាននិពន្ធដោយសាក្សីរូបនេះ រួមទាំងអត្ថបទសារព័ត៌មានសហកាលមួយឈុតរបស់គាត់ផងថា "នាំទៅដល់ការស្វែងរកការពិត"[27] ហើយបានដាក់ឯកសារនេះទៅក្នុងសំណុំរឿង។ សំណើសុំពុំបានបង្ហាញពីមូលដ្ឋានសម្រាប់ឱ្យអង្គជំនុំជម្រះលើកយកមកពិចារណាឡើងវិញចំពោះសេចក្តីសម្រេចពីមុនរបស់ខ្លួននោះឡើយ។ បន្ថែមលើសៀវភៅនេះ មានឯកសារមានតិចជាង១០បន្ថែមទៀត ដែលមាននៅក្នុងសំណុំរឿងក៏បាននិពន្ធដោយសាក្សី TCW-624 ឬក៏យោងពីសកម្មភាពផ្សេងៗគាត់នៅទីក្រុងភ្នំពេញ[28]។

១១. ជាចុងក្រោយ មេធាវីការពារក្តីអះអាងថា សក្ខីកម្មរបស់សាក្សី TCW-624 នឹង "ជាសក្ខីកម្មគ្មានសារសំខាន់ជាសារវ័ន្ត" ដើម្បីនឹងបន្ថែមទៅលើសក្ខីកម្មរបស់លោក Al Rockoff[29] ទេ។ គេគ្មានមូលដ្ឋានខាងអង្គហេតុសម្រាប់ការអះអាងនេះឡើយ។ លោក Rockoff គឺជាអ្នកថតរូប ចំណែកឯសាក្សី TCW-624 គឺជាអ្នកសារព័ត៌មានដែលបានសរសេររឿងរ៉ាវជាច្រើនអំពីកម្ពុជានៅមុន ក្នុងពេល និងក្រោយរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ ខណៈដែលសាក្សី TCW-624 អាចធ្លាប់នៅជាមួយលោក Al Rockoff ក្នុងពេលខុសគ្នាៗក្នុងរង្វង់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏ដោយ ក៏គេគ្មានសញ្ញាបង្ហាញណាមួយដែលថា ពួកគេបាននៅជាមួយគ្នាគ្រប់ពេលដែលពាក់ព័ន្ធទាំងនោះដែរ។ សាក្សី TCW-624 ធ្លាប់បានធ្វើដំណើរទៅកន្លែងផ្សេងៗនៃទីក្រុងភ្នំពេញ ឧទាហរណ៍ដូចជាទៅធ្វើសម្ភាសន៍ ឬប្រមូលព័ត៌មានដើម្បីបោះផ្សាយក្នុងអត្ថបទសារព័ត៌មាន។ វាជាការសមហេតុផលដែលនិយាយថា ចំណេះដឹងរបស់សាក្សី TCW-624 អំពីព្រឹត្តិការណ៍ទាំងនោះ និងលក្ខខណ្ឌផ្សេងៗទៀតដែលពាក់ព័ន្ធនៅក្នុងប្រទេស អាចថាបានដឹងយ៉ាងពិស្តារជាងលោក Rockoff ។ ការពិតទាំងនេះតែមួយគត់អាចផ្តល់មូលដ្ឋានមួយឱ្យគេអះអាងបានថា ខណៈដែលសក្ខីកម្មរបស់សាក្សីទាំងពីររូបអាចជា *ការបន្ថែមការគាំទ្រឱ្យគ្នាទៅវិញទៅមក* ក្នុងពេលជាច្រើនក៏ដោយ ក៏វាមិនច្រំដែល ដូចដែលមេធាវីការពារក្តីបានអះអាងដែរ។ ក្នុងរឿងក្តី *Naletilić* និង *Martinović* (2000) ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានកំណត់ចរិកលក្ខណៈថា "ភស្តុតាងមានលក្ខណៈច្រំដែល" ដោយសារតែ "សាក្សីជាច្រើនផ្តល់អង្គហេតុស្រដៀងគ្នា"[30]។ ការកំណត់ចរិកលក្ខណៈដូច្នេះមិនអាចអនុវត្តបានឡើយសម្រាប់ករណីនៅទីនេះ។

---

[26] **E236/1/4/2** សំណើ, *ដូចខាងលើ,* ត្រង់កថាខណ្ឌទី៩។ **E236/1/1/3** ចម្លើយតប TCCP-1, កំណត់សម្គាល់ខាងដើមលេខ៩ ត្រង់កថាខណ្ឌទី៨។

[27] **E260** អនុស្សរណៈជូនចំពោះភាគី៖ "ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីៗចូលក្នុងសំណុំរឿងពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី [ឈ្មោះលុបចេញ]", ១៨ មករា ២០១៣, ត្រង់កថាខណ្ឌទី៦។

[28] **D108/28.29**, **D199/26.2.220**, **D313/1.2.44**, **D313/1.2.52**, **D313/1.2.64**, **D313/1.2.65**, **D313/1.2.68**, **D365/1.1.23**, **E131/1/13.4**, **E131/1/13.5** [មិនដាក់បញ្ចូលចំណងជើងទេដើម្បីការពារអត្តសញ្ញាណសាក្សី]។

[29] **E236/1/4/2** សំណើ, កំណត់សម្គាល់ខាងដើមលេខ៧, ត្រង់កថាខណ្ឌទី១១។

[30] *រដ្ឋអាជ្ញា ទល់នឹង Mladen Naletilić និង Vinko Martinović*, សំណុំរឿងលេខ: IT-98-34-PT, សេចក្តីសម្រេចលើញត្តិកែតម្រូវរបស់អយ្យការសុំឱ្យអនុម័តវិធាន៩៤*ស្ទួនពីរ* នៃនីតិវិធី (សេចក្តីថ្លែងការណ៍ជាផ្លូវការ) និងលើញត្តិរបស់រដ្ឋអាជ្ញាសុំឱ្យយកវិធីយកសក្ខីកម្ម

១២. ដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះ **ច្រានចោល** សំណើនេះទាំងស្រុង និង**ចាត់ចែង** ដើម្បីស្តាប់សក្ខីកម្មសាក្សី TCW-624 តាមរយៈប្រព័ន្ធសោតទស្សន៍៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក William SMITH** សហព្រះរាជអាជ្ញារង | | [signature] |

(វិធីយកសក្ខីកម្មរបស់សាក្សីក្រោមសម្បថនៅក្រៅតុលាការ) ដើម្បីប្រើប្រាស់ក្នុងសវនាការ (វិធាន៧១), ១០ វិច្ឆិកា ២០០០ (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY), ព្រឹត្តិប័ត្រតុលាការបំពេញបន្ថែម លេខ២០។